**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ការិយាល័យអ្នកនាំពាក្យ**

# សេចក្តីបដិសេធ

ថ្មីៗនេះមានបុគ្គល ឬក្រុមខិលខូចនៅតែបន្តប្រើប្រាស់ឈ្មោះ និងរូបភាព **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើតគណនីតេឡេក្រាមក្លែងក្លាយឈ្មោះថា **"CEO. H.E HENG Sour" (@HENG_Souradmin)** និងរូបភាព **ឯកឧត្តមរដ្ឋមន្ត្រី** រួមជាមួយថ្នាក់ដឹកនាំក្រសួងក្នុងកម្មវិធីមួយ មកប្រើជារូបប្រូហ្វាលក្រុមតេឡេក្រាមឈ្មោះ **"ប្រាក់ចំណេញ ROI ប្រចាំថ្ងៃរបស់ OCIC ការវិនិយោគ"** ក្នុងចេតនាបោកប្រាស់សាធារណជនឱ្យយល់ថា ជារបស់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ការិយាល័យអ្នកនាំពាក្យ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជនថា គណនីតេឡេក្រាម **"CEO. H.E HENG Sour" (@HENG_Souradmin)** មិនមែនជាគណនីរបស់ **ឯកឧត្តម ហេង សួរ** នោះទេ ហើយ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏មិនមានជាប់ពាក់ព័ន្ធជាមួយនឹងក្រុមតេឡេក្រាមឈ្មោះ **"ប្រាក់ចំណេញ ROI ប្រចាំថ្ងៃរបស់ OCIC ការវិនិយោគ"** នោះដែរ។ ក្រសួងមិនទទួលខុសត្រូវនូវរាល់ការបាត់បង់អត្ថប្រយោជន៍ណាមួយដែលបង្កដោយគណនីតេឡេក្រាម ឬក្រុមតេឡេក្រាមខាងលើនោះឡើយ។ ដោយឡែក **ឯកឧត្តម ហេង សួរ** មានគណនីបណ្តាញទំនាក់ទំនងសង្គមផ្លូវការដូចខាងក្រោម៖

១. ហ្វេសប៊ុកផ្លូវការគឺ ៖ https://www.facebook.com/hengsour4all
២. តិកតុកផ្លូវការគឺ ៖ https://www.tiktok.com/@hengsour
៣. តេឡេក្រាមផ្លូវការគឺ ៖ https://t.me/HENG_Sour

ក្រសួង សូមព្រមានដល់ម្ចាស់គណនីតេឡេក្រាមក្លែងក្លាយ និងម្ចាស់ក្រុមតេឡេក្រាមខាងលើ ឱ្យលុបចោលនូវគណនីតេឡេក្រាម និងរូបភាពទាំងអស់របស់ **ឯកឧត្តម ហេង សួរ** ជាបន្ទាន់។ ទន្ទឹមនឹងនេះ ក្រសួងសូមស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការស៊ើបអង្កេត និងចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានម៉ឺងម៉ាត់ចំពោះករណីនេះ។

អាស្រ័យដូចបានជម្រាបខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងបង្កើនការប្រុងប្រយ័ត្នចំពោះករណីក្លែងបន្លំនេះ។

ថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥